ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ : ៦០៩ អទស

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមការងារគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
## និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ១៨៣ សសរ.ធទឧ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោងថ្នាក់ជាតិ ប្រចាំក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុស្សរណៈយោគយល់គ្នារវាងភ្នាក់ងារទឹកបារាំង (Loire-Bretagne Water Agency) និងអាជ្ញាធរទន្លេសាប ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២
- បានឃើញអនុស្សរណៈយោគយល់គ្នា រវាងអាជ្ញាធរទន្លេសាប និងការិយាល័យអន្តរជាតិនៃទឹក (The International Office for Water) ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣
- សេចក្តីសម្រេចលេខ ០២៧/១៣ អទស ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន
- យោងតាមការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប

# សម្រេច

**ប្រការ ១._**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **លឹម ពុយ** | អនុប្រធានអាជ្ញាធរទន្លេសាប | ប្រធាន |
| ២- លោក **អ៊ុក បញ្ញារិទ្ធ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក **លឹម ឧទ្ធី** | អនុប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | អនុប្រធាន |
| ៤- លោកស្រី **ប្រាក់ ចាន់វឌ្ឍនា** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | អនុប្រធាន |
| ៥- លោក **ប៉ុន ឧឌ្ឍី** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | អនុប្រធាន |
| ៦- លោក **ខ្វាន់ ឥន្ត្រា** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៧- លោក **នួច សំណាង** | ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន | សមាជិក |
| ៨- លោក **ខូច វេងសុខ** | ប្រធានការិយាល័យធនធានរ៉ែ | សមាជិក |
| ៩- លោក **សុខ វ៉ាយ៉ុង** | ប្រធានការិយាល័យអភិរក្ស | សមាជិក |

**ប្រការ ២._**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលដល់ការអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន
- កំណត់បទដ្ឋានបច្ចេកទេស និងវិធីសាស្ត្រសិក្សាស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីរៀបចំផែនការនៃការប្រើប្រាស់ធនធានទឹកនៃអាងស្ទឹង ប្រកបដោយនិរន្តរភាព
- ទទួលខុសត្រូវ និងអនុវត្តគម្រោងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ហើយធានាបាននូវសុក្រឹតភាព
- រៀបចំរបាយការណ៍វឌ្ឍនភាពអនុវត្តគម្រោង ជូនថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗទៀត ដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន។

**ប្រការ ៣ ._**

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប ឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥._**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ពុធ ១២ រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**
**និងជាប្រធានអាជ្ញាធរទន្លេសាប**

**ចៅ_ជេដ្ឋា**

**ចម្លងជូន៖**

- ក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ